# ដុំគូបដ៏មានតំលៃ

## ការជួញដូរមនុស្ស- ការពារតាមរយៈការអប់រំ

## 1 ១.តើអ្វីទៅជាតំលៃនៃជីវិតរបស់មនុស្ស?



- មនុស្សទាំងនេះគឺតំណាងអោយប្រជាជាតិនៅលើពិភពលោក ពួកគេស្លៀកពាក់ខុសៗគ្នា រស់នៅខុសៗគ្នា និងមានប្រពៃណីផ្សេងៗពីគ្នា។
- ប៉ុន្តែទាំងអស់គ្នាមានតំលៃស្មើរគ្នា ។(*ចង្អុលលើរូបស្ត្រីម្នាក់*)ហើយសួរថា បើឪពុករបស់ស្ត្រីនេះប្រឈមនឹងសេចក្តីស្លាប់ តើនាងនឹងធ្វើអ្វីខ្លះដើម្បីជួយសង្គ្រោះជីវិតរបស់ឪពុក? រឺក៏បងប្រុសបុរស់ម្នាក់នេះជួបគ្រោះថ្នាក់ តើគាត់នឹងជួយសង្គ្រោះជីវិតបងប្រុសរបស់គាត់យ៉ាងដូចម្តេច?
- មនុស្សម្នាក់ៗនឹងលះបង់គ្រប់យ៉ាងដើម្បីជួយជីវិតមនុស្សដែលខ្លួនស្រលាញ់ ព្រោះជីវិតមនុស្សម្នាក់ៗមានតំលៃណាស់។ **ចំណុចមួយដែលយើងមានដូចគ្នាគឺម្នាក់ៗប្រឹងប្រែងចង់បានការល្អស្រដៀងៗគ្នា។**

## 2 ២.តើយើងទាំងអស់គ្នាចង់បានអ្វីខ្លះនៅក្នុងជីវិត?



- **ការអភិវឌ្ឍន៏ផ្នែកសេដ្ឋកិច្ច** (*ចង្អុលលើរូបលុយ*) តើអ្នកចង់រកលុយអោយបានច្រើនដែររឺទេ? តើអ្នកប្រើលុយធ្វើអ្វីខ្លះ? យើងអាចប្រើលុយដើម្បីទិញរបស់ដែលយើងត្រូវការ រឺ ចង់បាន ដូចជា ខោអាវ ទូស័ព្ទថ្មី រឺ បង់លុយសំរាប់ការរៀនសូត្រ។
- **ការសិក្សា** (*ចង្អុលលើរូបសៀវភៅ និងកុមារ*) ហេតុអ្វីបានជាកាសិក្សាមានសារៈសំខាន់? យើងចង់អោយកូនយើងខំប្រឹងប្រែងរៀនសូត្រដើម្បីអោយគេមានអនាគតល្អ មានការងារល្អ និងអាចរកលុយបានច្រើន។
- **ភាពសមរម្យស្មើរគ្នា** យើងប្រឹងប្រែងដើម្បីអោយបានការអប់រំខ្ពស់ មានលុយច្រើន ព្រោះយើងចង់បានសិទ្ធិនិងកាគោរពអោយតំលៃស្មើរៗគ្នា មិនថាយើងជានរណាឬរស់នៅទីណានោះទេ(*ចង្អុលលើរូបមនុស្សទាំងបីនាក់*)។ **ទាំង៣ចំណុចនេះជាដើមចមនៃការនាំទៅរកការរំលោភបំពាន។**

## 3 ៣.តើនរណាខ្លះដែលយើងគោរព?



- **អ្នកដឹកនាំសាសនា** ដោយសារយើងសង្ឃឹមថាពួកគាត់អាចបង្រៀនយើងអោយចេះស្វែងរកសេក្តីសុខ និង ចេះស្វែងរកព្រះ។
- **ប្តី រឺក៏មិត្តប្រុស** ដោយសារពួកគាត់បង្ហាញសេចក្តីស្រលាញ់ដោយការផ្តល់លុយ ឬ ការលើកទឹកចិត្ត។
- **គ្រួសារ រឺ មិត្តភក្រ័** ឪពុកម្តាយ មីង និង អ្នកជិតខាង ដោយសារតែពួកគាត់ជួយមើលថៃយើងពេលយើងនៅក្មេង។
- **អ្នកជំនួញ អ្នកមាន** ដោយសារពួកគាត់មានលុយ មានឋានៈ និង មានកិត្តិយស។

## ៤.តើហេតុអ្វីបានជាកុមារទាំងនេះធ្វើដំណើរចាកចេញ  តើពួកគេទៅណា? 4



- ដោយសារមានអ្នកមានម្នាក់បានអោយលុយដល់គ្រួសារនេះ និងបានសន្យាថាយកកូនពួកគាត់ទៅធ្វើការ ឬ លេងកីឡានៅក្រៅប្រទេស។(*ចង្អុលលើរូបគ្រួសារលើកដៃលាគ្នា*) អ្នកមាននេះក៏បានសន្យាថាផ្ញើរលុយអោយគ្រួសារកុមារជារៀងរាល់ខែ។
- ដោយសារមានអ្នកដឹកនាំសាសនាបានសន្យានឹងជួយក្មេងក្នុងគ្រួសារនេះអោយទៅរៀននៅទីក្រុង។(*ចង្អុលលើរូបគ្រួសារអោបគ្នាខាងលើ*) ពួកគាត់មិនសប្បាយដោយឃើញកុមារចាកចេញទៅឆ្ងាយ  ប៉ុន្តែសប្បាយដោយកូនពួកគាត់មានអ្នកមើលថែ និង មានការអប់រំល្អ។
- ដោយសារម្តាយមីងបានសន្យាផ្តល់ការងារក្នុងភោជនីយដ្ឋាននៅឯទីក្រុងដល់កុមារធ្វើជាមួយមិត្តគាត់ម្នាក់។(*ចង្អុលលើរូបក្មេងស្រីអើតតាមបង្អួចឡាន*) គាត់បានសន្យាថានាងនឹងរកលុយបានច្រើន ហើយការងារក៏សប្បាយ។
- មនុស្សទាំងអស់នេះបានសំរេចចិត្តបញ្ជូនកូនរបស់ខ្លួនឲ្យទៅឆ្ងាយដោយសារតែបានទទួលការសន្យាពីមនុស្សដែលពួកគាត់ទុកចិត្ត។ (*ចង្អុលលើរូបក្មេងស្រីត្រូវគេខ្ទប់មាត់)* ប៉ុន្តែ កុមារម្នាក់នេះត្រូវគេចាប់ទៅទាំងបង្ខំដោយមិនដឹងជាគេយកទៅទីណាឡើយ។

**គ្រួសារទាំងនេះជឿថាខ្លួនកំពុងសំរេចចិត្តយ៉ាងត្រឹមត្រូវ ពួកគាត់គិតថាកន្លែងដែលកូនៗពួកគាត់ទៅនៅ ប្រសើរជាងផ្ទះរបស់ខ្លួន រឺ ពួកគាត់គិតថា គាត់គ្មានជំរើសណាផ្សេងទេ។**

## ៥.តើអ្វីជាការពិតហើយអ្វីជាការឆបោក? 5



- ប្តីរឺក៏មិត្តប្រុសដែលធ្វើការដើម្បីផ្តល់សេចក្តីសុខដល់មនុស្សដែលខ្លួនស្រលាញ់ មិនវាយដំប្រពន្ធរឺមិត្តស្រីរបស់ខ្លួននោះទេ ហើយពួកគេនោះគឺជាមនុស្សល្អ។ **ប៉ុន្តែបើពួកគេបង្ខំអោយប្រពន្ធរឺមិត្តស្រីរបស់ខ្លួនរួមភេទជាមួយមនុស្សប្រុសដទៃជាថ្នូរនឹងលុយរឺគ្រឿងញៀន នោះបញ្ជាក់ថាគេជាមនុស្សឆបោក។**
- បើមានអ្នកដឹកនាំសាសនាផ្សេងៗដែលរស់នៅក្បែរអ្នក ចេះនិយាយភាសារបស់អ្នក មកលេងផ្ទះរបស់អ្នក ហើយចង់បង្រៀនអ្នកអោយចេះស្វែងរកព្រះ អ្នកទាំងនោះគឺជាមនុស្សល្អ។ **ប៉ុន្តែមានមនុស្សខ្លះមកហើយស្លៀកពាក់ដូចជាអ្នកដឹកនាំសាសនា រួចអោយលុយជាថ្នូរនឹងការនាំយកកូនយើងទៅ អ្នកទាំងនោះគឺជាមនុស្សឆបោក។**
- បើមានអ្នកមានមកធ្វើមនុស្សធម៌ កសាងសាលារៀន ចែកថ្នាំពេទ្យ  ជីកអណ្តូងទឹកនៅក្នុងភូមិ អ្នកទាំងនេះគឺជាមនុស្សល្អ។ **ប៉ុន្តែបើគេអោយលុយជាថ្នូរនឹងការនាំយកកូនយើងទៅ អ្នកទាំងនោះគឺជាមនុស្សឆបោក។**
- អ្នកជិតខាង ម្តាយមីង រឺម្តាយដែលជួយកូនខ្លួនអោយបានទៅរៀន និងមានការងារ នោះគឺជាមនុស្សល្អ។  ប៉ុន្តែបើមានស្ត្រីណាម្នាក់មកយកកូនយើងទៅរៀន រឺទៅធ្វើការនៅប្រទេសផ្សេង ដោយសន្យាចេញថ្លៃសោហ៊ុយធ្វើដំណើរតែបង្ខាំងឯកសារទុក អ្នកនោះគឺជាមនុស្សឆបោក។

## ៦. តើកុមារនៅឯណា? 6



- មនុស្សដែលយើងទុកចិត្តបានបោកប្រាស់យើង គ្រួសារជាច្រើនបានជឿលើការកុហក ហើយឥឡូវនេះកូនៗរបស់ពួកគាត់ត្រូវបានគេបង្ខំឲ្យធ្វើការងារឲ្យមនុស្សដ៏មានគ្រោះថ្នាក់។ (*ចង្អុលលើរូបដៃជាប់ខ្នោះ*) ពួកគេត្រូវបានឃុំឃាំងគ្មានផ្លូវរត់រួចឡើយ។
- (*ចង្អុលលើរូបនៅកណ្តាលខាងស្តាំនិងខាងឆ្វេង*) កុមារជាច្រើនត្រូវបានគេបង្ខំឲ្យធ្វើការក្រោមកំដៅថ្ងៃនៅទីវាល រឺ នៅលើទូកនេសាទត្រី។ ពួកគេត្រូវធ្វើការពីព្រលឹមដល់យប់ជ្រៅ ពួកគេបរិភោគមិនគ្រប់គ្រាន់ ហើយគេងក៏មិនគ្រប់គ្រាន់ដែរ។ ពួកគេនឹងត្រូវរងការវាយដំ រឺ សំលាប់បើហ៊ានសំរាក រឺ លេងសប្បាយ។
- (*ចង្អុលលើរូបកុមារដែលអង្គុយលើឥដ្ឋគ្មានគ្រែគេង*) កុមារជាច្រើនត្រូវគេបង្ខំឲ្យធ្វើការទាំងយប់ដើម្បីបំរើផ្លូវភេទ ត្រូវគេចាប់បង្ខំ រំលោភក្នុង១យប់ៗជួនកាលរហូតដល់ទៅ៣០នាក់។
- (*ចង្អុលលើរូបកុមារីខាងលើ*) កុមាររងនូវការឈឺចាប់ ត្រូវគេឃុំឃាំងក្នុងបន្ទប់តូចមួយ និងបង្ខំឲ្យប្រើថ្នាំញៀនដើម្បីកុំឲ្យនាងតដៃ ហើយឲ្យនាងទទួលស្គាល់ថា នាងគ្មានជំរើសណាក្រៅពីតែងខ្លួនឲ្យស្អាត ធ្វើពុតជារីករាយបំរើផ្លូវភេទ ជាថ្នូរនឹងសុវត្ថភាពផ្ទាល់ខ្លួន ដោយភ្លេចគិតថាជីវិតមនុស្សគ្រប់រូបសុទ្ធតែមានតំលៃ ហើយរូបនាងក៏មានតំលៃដែរ។ **នាងនឹងស្លាប់ដោយសារការធ្វើបាប ដោយបាក់កំលាំង រឺ ដោយជំងឺផ្សេងៗបើគ្មាននរណាម្នាក់ជួយពួកនាង។**

## ៧. មានសេចក្តីសង្ឃឹមសំរាប់កុមារនិងគ្រួសារ 7



- (*ចង្អុលលើរូបគ្រួសារខាងលើផ្នែកខាងឆ្វេង*) ត្រូវការពារគ្រួសារឲ្យបានល្អ កុំឲ្យពួកគេទៅរៀន រឺ ទៅធ្វើការជាមួយ**នរណា**ជាថ្នូរនឹងលុយ។ កុំឲ្យពួកគេទៅឆ្ងាយជាមួយ**នរណា**ដែលចេញសោហ៊ុយធ្វើដំណើរឲ្យដោយងាយៗ។ កុំឲ្យកូនលោកអ្នក រឺ ឯកសារសំគាល់ខ្លួនកូនលោកអ្នកទៅ**នរណា**ម្នាក់ឲ្យសោះ។
- (*ចង្អុលលើរូបស្ត្រីនិយាយទូរស័ព្ទ*) បើយើងឃើញ រឺ ឮដំណឹងថាមាននរណាយកកុមារណាម្នាក់ចេញពីផ្ទះ រឺ បង្ខំអោយធ្វើការនៅកន្លែងគ្រោះថ្នាក់ណាមួយ យើងត្រូវជូនដំណឹងភ្លាម។ កុមារទាំងនោះមានតំលៃណាស់ ហើយពួកគេសាកសមនឹងទទួលការការពារពីយើង។ បើបានឃើញ សូមទាក់ទងមកមន្ត្រីអាជ្ញាធរដើម្បីជួយអន្តាគមន៍។
  **សូមទំនាក់ទំនងមកលេខទូរស័ព្ទ**______________________________________
- (*ចង្អុលលើរូបខ្នោះច្រវ៉ាក់*) ពេលខ្លះមានគ្រួសារមួយចំនួនមិនព្រមទទួលយកកុមាររងគ្រោះដែលរត់រួច រឺត្រូវបានសង្គ្រោះមកវិញទេ គ្រួសារទាំងនោះខ្មាស់គេដោយព្រោះតែរឿងរ៉ាវដែលបានកើតឡើង និងជំងឺដែលកុមារមាន ហើយបោះបង់កុមារនោះចោល។
- (*ចង្អុលលើរូបទ្វាបើកចំហ*) តាមរយៈការបើកទ្វាចិត្តចំហរទទួលកុមាររងគ្រោះ នោះកុមារនិងក្រុមគ្រួសារអាចព្យាបាលរបួសក្នុងចិត្ត និងមានសេរីភាពជាថ្មីឡើងវិញ។
- ទោះបីជាពួកគេធ្លាប់រងទុក្ខឈឺផ្សា តែពួកគេអាចទទួលការប្រោសឲ្យជាទាំងស្រុងឡើងវិញបាន។

### ប្តូរទៅប្រើដុំគីបដំណឹងល្អ៖

**តើខ្ញុំអាចប្រាប់រឿងមួយទៀតពីការបើកទ្វារចំហនេះដល់អ្នកបានដែររឺទេ?**

ព្រះជាម្ចាស់បានបើកទ្វាររងចាំអ្នក ដើម្បីឲ្យអ្នកបានឭដំណឹងល្អអំពីព្រះយេស៊ូវគ្រីស្ទ ដែលជាដំណឹងល្អនៃការប្រោសឲ្យជា ការស្តារឡើងវិញ និង សេចក្តីសង្ឃឹមនៃសេរីភាពដ៏ពិតតែមួយ។

# របាយការណ៍ស្ថិតិ

- ជារៀងរាល់៣០ វិនាទីម្តងមានកុមារម្នាក់ត្រូវបានរងគ្រោះដោយសារការរំលោភបំពាននិងជួញដូរ។
- មធ្យមភាគនៃកុមារអាយុ ១៣ឆ្នាំ ត្រូវបានរងគ្រោះដោយសារការរំលោភបំពាននិងជួញដូរ នៅសហរដ្ឋអាមេរិច។
- ក្នុងចំណោមប្រទេស ១៩២ គឺមាន ១៦១ ប្រទេសដែលមានការរំលោភបំពាននិងជួញដូរមនុស្សកើតឡើង។
- ៩៦% នៃស្ត្រីបំរើផ្លូវភេទដែលចង់រត់គេចខ្លួនអោយមានសេរីភាព ប៉ុន្តែពួកគេមិនអាចធ្វើបាន។
- ឧស្សាហកម្មជួញដូរមនុស្សមានទំហំទឹកប្រាក់ ៣២ ពាន់លានដុល្លាក្នុង១ឆ្នាំ។
- មានការប្រមាណមើលថា ៧០%នៃបុរសទៅរកសេវាកម្មផ្លូវភេទ។
- ជាង២៧លាននាក់ត្រូវបានធ្លាក់ជាទាសករផ្លូវភេទនៅជុំវិញពិភពលោក លើសជាងទាសករផ្លូវភេទនៅអាហ្វ្រិកពីរដង។

# ចំណាត់ការដ៏ប្រសើរ

**ក្នុងនាមជាអង្គការ រឺ តំណាងភ្នាក់ងារនីមួយៗ ៖**

- យើងមិនត្រូវបង្ហាញរូបភាពមុខមាត់របស់កុមាររងគ្រោះជាសាធារណៈជាដាច់ខាត។
- យើងមិនត្រូវចែកចាយរឿងជនរងគ្រោះដោយប្រើឈ្មោះពិត រឺ ទីកន្លែងពិតជាដាច់ខាត។
- យើងមិនត្រូវចែកចាយរឿងអំពីកុមាររងគ្រោះដល់ប្រព័ន្ធផ្សព្វផ្សាយពត៌មាន បើមិនទាន់មានការអនុញ្ញាតពីកុមាររងគ្រោះ រឺ អាណាព្យាបាល។
- យើងនឹងផ្តល់ពត៌មានអោយបានត្រឹមត្រូវ  មិនបន្ថែម រឺបំភ្លើសការពិត។
- គ្រប់ទាំងរូបភាព និងពត៌មានរបស់ជនរងគ្រោះត្រូវតែត្រឹមត្រូវច្បាស់លាស់មុនពេលបង្ហាញនៅក្នុងទំព័រកាសែត facebook, blogs, Twitter, etc.
- ត្រូវតែមានការយល់ដឹងអោយបានខ្ពស់ចំពោះអំពើជួញដូរមនុស្ស នៅពេលជួបហេតុការណ៍នេះត្រូវសរសេរពត៌មានចុះ ដូចជា ឈ្មោះ អាយុ ទីកន្លែងកើតហេតុ  ហើយត្រូវផ្តល់ពត៌មាននេះដល់មេក្រុមការងារចាត់ការបន្តតាមនិតិវិធីនៃច្បាប់។

# ជំហានអនុវត្តន៍

**ការយល់ដឹងបន្ថែម** លោកវីល្យាម វីលបើហ្វសបាននិយាយថា *"អ្នកអាចមានជំរើសផ្លូវផ្សេង ប៉ុន្តែអ្នកមិនអាចនិយាយថាអ្នកអត់ដឹងបានទេ។ ដោយព្រោះអ្នកបានដឹង អ្នកត្រូវងើបឈរឡើងប្រយុទ្ធប្រឆាំង ដោយផ្សព្វផ្សាយពត៌មាននេះដល់មនុស្សដែលយើងស្គាល់អោយបាន១០នាក់ និងមនុស្សដែលយើងមិនស្គាល់ ១០នាក់"*។

**ថ្វាយដង្វាយ** លុយដែលយើងថ្វាយគឺជាចលករជំរុញអោយការប្រយុទ្ធប្រឆាំងការជួញដូរមនុស្សបន្តទៅមុខ ដូច្នេះសូមរួមចំណែកជួយឧបត្ថមដល់អង្គការទាំងឡាយណាដែលប្រយុទ្ធប្រឆាំងនឹងការជួញដូរនេះ។

**អធិស្ឋាន** ព្រះយេស៊ូវបានយាងមកដើម្បីដោះមនុស្សអោយមានសេរីភាព ដូច្នេះសូមអធិស្ឋានជាមួយនឹងទ្រង់ដើម្បីអោយកិច្ចការនេះសំរេចតាមព្រះហឫទ័យទ្រង់ ហើយជួយមនុស្សជាប់ទោសអោយមានសេរីភាពឡើងវិញ។

©2017 e3 Partners Ministry / e3 Resources